# ដំណើរការរៀបចំគោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជន ឆ្ពោះទៅរកការចូលរួមចំណែកនៅក្នុងការដាំស្តារព្រៃឈើនៅកម្ពុជា

## សេចក្តីផ្តើម

ការចូលរួមដាំឈើដោយប្រជាពលរដ្ឋ និងវិស័យឯកជន ត្រូវបានលើកទឹកចិត្តដោយរាជរដ្ឋាភិបាលកម្ពុជាដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើជាពិសេសការជំរុញឱ្យមានការចុះបញ្ជី "ព្រៃឯកជន"។ ព្រៃឯកជនត្រូវបានកំណត់ដោយប្រកាសលេខ៣២៧ ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី "វិធានព្រៃឯកជន" ក្នុងគោលបំណងជំរុញ និងលើកទឹកចិត្តដល់រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លីក្នុងការចូលរួមដាំដុះឈើលើដីកម្មសិទ្ធិឯកជន ដើម្បីបង្កើនប្រភពផ្គត់ផ្គង់ផល អនុផលព្រៃឈើចេញពីចម្ការឈើដាំសម្រាប់កែច្នៃ ប្រើប្រាស់ក្នុងស្រុក និងនាំចេញ។ ដើម្បីសម្រេចបាននូវការអនុវត្តតាមខ្លឹមសារប្រកាសនេះ រដ្ឋបាលព្រៃឈើ ដែលមាន **លោកបណ្ឌិត លី ម៉េងស៊ាង** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន បានផ្តួចផ្តើមដឹកនាំរៀបចំគោលការណ៍ណែនាំ ស្តីពី "**ការបង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា**" នៅឆ្នាំ២០១៨ ប៉ុន្តែដោយសារធនធានមានកម្រិត ការពិគ្រោះយោបល់ជាមួយបណ្តាអង្គភាពក្រោមឱវាទរដ្ឋបាលព្រៃឈើទាំងថ្នាក់ជាតិ និងក្រោមជាតិ ដើម្បីទទួលបានព័ត៌មានសម្រាប់រៀបចំគោលការណ៍ណែនាំនេះ មិនមានវិសាលភាពទូលំទូលាយ។ នៅចុងឆ្នាំ២០១៩ នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន បានសហការជាមួយគម្រោង "Integrating the development of guidelines and incentives for piloting the establishment of small-scale private *Dalbergia* plantation" ដែលឧបត្ថម្ភថវិកាដោយសហគមន៍អឺរ៉ុប (European Union) តាមរយៈលេខាធិការដ្ឋានអនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃ និងរុក្ខជាតិរងគ្រោះជិតផុតពូជ (Secretariat of the Convention on International Trade in Endangered Species of Wild Fauna and Flora-CITES) និងគម្រោង "The registration of small-scale private forest plantation in Cambodia" ដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េ តាមរយៈអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (The Asian Forest Cooperation Organization-AFoCO) ចុះប្រមូលព័ត៌មាន និងធាតុចូលសំខាន់ៗ ក្នុងការចងក្រង និងរៀបចំ "**គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា**" ដោយបានរៀបចំកិច្ចប្រជុំដោយផ្ទាល់ និងប្រជុំពីចម្ងាយ (Zoom meeting) និងសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនលើក ដោយមានការចូលរួមពីមន្ត្រីរដ្ឋបាលព្រៃឈើទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រឹះស្ថានអប់រំ វិស័យឯកជន អ្នកសិក្សាស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធវិស័យព្រៃឈើ។



*រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់ និងចងក្រង ឯកសារគោលការណ៍ណែនាំសម្រាប់បង្កើតនិងចុះបញ្ជីព្រៃឯកជន ត្រូវបានរៀបចំនៅថ្ងៃទី២៦-២៧ ខែវិច្ឆិកា ឆ្នាំ២០២០*

## ស្វែងយល់អំពីគោលការណ៍ណែសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជន

នៅក្នុងគោលការណ៍ណែនាំ "**ព្រៃឯកជន** ត្រូវបានកំណត់ ជាចម្ការឈើដែលបានដាំ ឬ ដើមឈើដុះដោយធម្មជាតិលើដីដែលបានចុះបញ្ជី និងផ្តល់ជាកម្មសិទ្ធិឯកជនក្រោមនីតិវិធី និងច្បាប់រដ្ឋ។ ព្រៃឯកជនសំដៅដល់ចម្ការព្រៃដាំដែលបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន ដែលជាកម្មសិទ្ធិករដីធ្លីនៅលើដីកម្មសិទ្ធិឯកជនរបស់ខ្លួនដោយទទួលសិទ្ធិកាន់កាប់ស្របតាមច្បាប់ភូមិបាល និងត្រូវបានចុះបញ្ជីទទួលស្គាល់ជាព្រៃឯកជនស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ និងប្រកាសស្តីពីវិធានព្រៃឯកជន"។

*លោក **គឹម សុបុណ្យ** ៖ "គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជានេះ អាចជាមគ្គុទេសក៍ជួយកម្មសិទ្ធិករដីធ្លី ឬនីតិបុគ្គលដែលមានបំណងចុះបញ្ជីព្រៃឯកជនរបស់ខ្លួន ស្វែងយល់អំពីដំណើរការបង្កើត និងចុះបញ្ជីព្រៃឯកជន ចំណេះដឹង និងជំនាញក្នុងការថែទាំចម្ការព្រៃឯកជន និងអត្ថប្រយោជន៍នានាពីរាជរដ្ឋាភិបាល។"*



*រូបភាព៖ លោក **គឹម សុបុណ្យ** ជាអនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃឈើដាំ និងព្រៃឯកជន និងជាមន្ត្រីគម្រោងចុះបញ្ជីចម្ការព្រៃឯកជននៅកម្ពុជា នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ និងចងក្រង ឯកសារគោលការណ៍ណែនាំសម្រាប់បង្កើតនិងចុះបញ្ជីព្រៃឯកជន ត្រូវបានរៀបចំនៅថ្ងៃទី២៦-២៧ ខែវិច្ឆិកា ឆ្នាំ២០២០*

*"គោលការណ៍នេះនឹងលើកទឹកចិត្តដល់វិស័យឯកជនចូលរួមដាំឈើ ដើម្បីរួមចំណែកសម្រេចបាននូវក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកប ដោយចីរភាព ឆ្នាំ២០១៦-២០៣០ ដែលធានាការអភិរក្ស ការស្តារ និងការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ី និងសេវាកម្មព្រៃឈើ ដោយបានកំណត់សូចនាករគោលដៅជាតិ ដោយសម្រេចឱ្យបានគម្របព្រៃឈើ ៥០% ត្រឹមឆ្នាំ២០៣០ ជាពិសេសការបង្កើតធនធានចម្កាឈើដាំ ដែលជាការរួមចំណែកកាត់បន្ថយសម្ពាធដល់ព្រៃឈើធម្មជាតិឱ្យស្របកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិ។"*

គោលការណ៍ណែនាំមាន៤ ជំពូក៖ **ជំពូកទី១ (សេចក្តីផ្តើម)** បង្ហាញអំពីនិយមន័យនៃព្រៃឯកជន គោលបំណង ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ ដែលគាំទ្រដល់ម្ចាស់ព្រៃឯកជន សិទ្ធិក្នុងកិច្ចដំណើរការដាំឈើ និងប្រើប្រាស់កិច្ចដំណើរការអាជីវកម្មដោយស្របច្បាប់។ **ជំពូកទី២ (គោលការណ៍ណែនាំសម្រាប់ការចុះបញ្ជីព្រៃឯកជន)** បង្ហាញអំពីជំហានជានីតិវិធី "គោលការណ៍ណែនាំ" សម្រាប់មន្ត្រីរដ្ឋបាលព្រៃឈើ រូបវន្តបុគ្គល នីតិបុគ្គល និងអ្នកពាក់ព័ន្ធស្វែងយល់ និងអនុវត្តការងារបង្កើត និងចុះបញ្ជីព្រៃឯកជន។ **ជំពូកទី ៣ (ការរៀបចំផែនការដាំឈើសម្រាប់ចម្ការឈើដាំ និងព្រៃឯកជន)** បង្ហាញអំពីគោលគំនិតសំខាន់ៗពាក់ព័ន្ធនឹងការជ្រើសរើសទីតាំង ការបង្កើតចម្ការឈើដាំ និងការរៀបចំផែនការដាំឈើជាដើម។ **ជំពូកទី៤ (ការប្រមូលផល និងយន្តការនៃការពិនិត្យចម្ការឈើដាំ និងព្រៃឯកជន)** បង្ហាញអំពីរបៀបនៃការប្រមូលផលឈើពីចម្ការឈើដាំ និងព្រៃឯកជន ការកត់ត្រាទិន្នន័យនៅក្នុងចម្ការឈើរួមមានសកម្មភាពដាំដុះ ប្រភេទឈើ ចំនួនដើម និងបរិមាណឈើដែលបានប្រមូលផល ដើម្បីបង្កភាពងាយស្រួលដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ក្នុងករណីចាំបាច់។

*លោក **ផង តុល** ប្រធានការិយាល័យព្រៃឯកជន និងដៃគូសហការ បានលើកឡើងថាគោលការណ៍ណែនាំនេះ គឺរៀបចំឡើងទៅតាមប្រកាសស្តីពីវិធានព្រៃឯកជន និងពន្យល់ថា៖ "ម្ចាស់ព្រៃឯកជនដែលបានចុះបញ្ជីចម្ការឈើដាំនៅលើដីឯកជនជាព្រៃឯកជន មានសិទ្ធិថែរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់និងចែកចាយ ផលិតផលរបស់ខ្លួនបាន។ ការដឹកជញ្ជូនផលិតផលឈើដែលមានប្រភពចេញពីព្រៃឯកជន ដើម្បីទៅផ្គត់ផ្គង់ ដល់អតិថិជន ឬទីផ្សារក្នុងស្រុក គឺមិនតម្រូវឱ្យមានលិខិតអនុញ្ញាត (LP) ឡើយ។"*



*រូបភាព៖ លោក **ផង តុល** ធ្វើបទបង្ហាញ "ប្រកាសស្តីពីវិធានព្រៃឯកជន" នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ និងចងក្រងឯកសារគោលការណ៍ណែនាំសម្រាប់បង្កើតនិងចុះបញ្ជីព្រៃឯកជន ត្រូវបានរៀបចំនៅថ្ងៃទី២៦-២៧ ខែវិច្ឆិកា ឆ្នាំ២០២០*

## នីតិវិធីសំខាន់ៗនៃដំណើការចុះបញ្ជីព្រៃឯកជននៅក្នុងគោលការណ៍ណែនាំ

យោងតាមប្រកាសលេខ៣២៧ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រៃឯកជនត្រូវបានចាត់ថ្នាក់តាមទំហំ៖ (១) ព្រៃឯកជនលក្ខណៈគ្រួសារ ដែល ផ្ទៃដីទំហំក្រោម១០ហិកតា (២) ព្រៃឯកជនទំហំតូច ដែលផ្ទៃដីទំហំចាប់ពី១០-១០០ហិកតា (៣) ព្រៃឯកជនទំហំមធ្យម ដែលផ្ទៃដីទំហំលើសពី១០០-១០០០ហិកតា និង (៤) ព្រៃឯកជនទំហំធំ ដែលផ្ទៃដីទំហំលើសពី ១០០០ហិកតាឡើងទៅ។ លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីព្រៃឯកជន រួមមាន៖ ១-ពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន ២-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន ៣-ឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី (លិខិតបញ្ជាក់ពីភូមិបាល ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) ៤-ប្លង់ទីតាំងដាំដុះឈើបង្កើតជាព្រៃឯកជន និង ៥-ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ពិសេសសម្រាប់នីតិបុគ្គល។



*រូបភាព៖ កិច្ចប្រជុំអន្តរនាយកដ្ឋាន ពាក់ព័ន្ធគោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា នៅថ្ងៃទី១៤ខែមករា ឆ្នាំ២០២១*

 

*រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីគោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា ត្រូវបាន រៀបចំនៅថ្ងៃទី២៦-២៧ ខែវិច្ឆិកា ឆ្នាំ២០២០*

រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនដែលជាកម្មសិទ្ធិករដីធ្លី ម្ចាស់ចម្ការឈើដាំ ឬដំណុះព្រៃធម្មជាតិ អាចប្រឹក្សាយោបល់ជាមួយមន្ត្រីជំនាញនៃនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជននៃរដ្ឋបាលព្រៃឈើ ឬ មន្ត្រីជំនាញនៃខណ្ឌរដ្ឋបាលព្រៃឈើ មុននឹងស្នើសុំចុះបញ្ជីព្រៃឯកជនរបស់ខ្លួន។

ដំណើរការនៃការស្នើសុំចុះបញ្ជីព្រៃឯកជនមាន ៣ជំហាន ដូចខាងក្រោម ៖

**ជំហានទី១ ការដាក់ពាក្យស្នើសុំ៖** កម្មសិទ្ធិករដីធ្លី បំពេញបែបបទស្នើសុំបង្កើត និងចុះបញ្ជីព្រៃឯកជន ដោយភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដាំដុះបង្កើតជាព្រៃឯកជន ប្រភេទឈើដាំ និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់

**ជំហានទី២ ការពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ៖** មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ពិនិត្យលើពាក្យស្នើសុំ និងឯកសារបញ្ជាក់សិទ្ធិកាន់កាប់ដីធ្លី ប្លង់ទីតាំងដាំដុះឈើបង្កើតជាព្រៃឯកជន ប្រភេទឈើដាំ និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ ចុះពិនិត្យ និងផ្ទៀងផ្ទាត់ទីតាំង និងរាយការណ៍ជូនថ្នាក់ដឹកនាំ ស្នើសុំការសម្រេច

**ជំហានទី៣ ការចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជន៖** ពិនិត្យ និងសម្រេចរបស់ស្ថាប័នមានសមត្ថកិច្ច ក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ម្ចាស់ព្រៃឯកជន ជូនកម្មសិទ្ធិករដីធ្លី។




*រូបភាព៖ ជំហានទាំង៣ នៃដំណើរការស្នើសុំចុះបញ្ជីព្រៃឯកជននៅកម្ពុជា*



*រូបភាព៖ ទស្សនកិច្ចចម្ការឈើដាំរបស់ក្រុមហ៊ុនឯកជន Grandis នៅខេត្តកំពង់ស្ពឺ*

វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជននេះ នឹងផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានដាក់ពាក្យស្នើចុះបញ្ជីព្រៃឯកជនក្នុងរយៈពេលមិនលើសពី ៤៥ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលពាក្យ ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ឯកសារបញ្ជាក់កម្មសិទ្ធិដីធ្លីស្របតាមច្បាប់ភូមិបាល (ថតចម្លងតាមច្បាប់ដើម)
- ទីតាំងដីស្នើសុំមានសុវត្ថិភាព
- ករណីដីដាំឈើត្រូវបានជួលពីឯកជនក្នុងរយៈពេលវែង ដោយមានកិច្ចសន្យាជួល និងការឯកភាពពីម្ចាស់អចលនវត្ថុក្នុងការចុះបញ្ជីជាព្រៃឯកជនដោយលាយលក្ខណ៍អក្សរ
- ប្រភេទឈើដែលបានដាំ យ៉ាងហោចណាស់បង្កើតជាគម្របដីលើសពី ៣៥ភាគរយ។

ដោយឡែក ករណីទីតាំងស្នើសុំចុះបញ្ជីពុំទាន់បានបំពេញគ្រប់លក្ខខណ្ឌខាងលើ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវរៀបចំលិខិតជូនដំណឹងដល់រូបវន្ត ឬនីតិបុគ្គលឯកជនវិញ ព្រមទាំងណែនាំឱ្យធ្វើការបំពេញបន្ថែម និងស្នើសុំសាជាថ្មីឡើងវិញ ។

លោកស្រី **លឹម សុភាព** ៖ "*គោលការណ៍ណែនាំស្តីពីការចុះបញ្ជីព្រៃឯកជននេះ នឹងរួមចំណែកក្នុងការពង្រីកការដាំស្តារព្រៃឈើនៅកម្ពុជា ពីវិស័យឯកជន ក្នុងទម្រង់ ជាចម្ការឈើ ឬក៏ទម្រង់កសិ-រុក្ខកម្មក្តី ហើយការផ្តល់ និងចែកកូនឈើដោយឥតគិតថ្លៃជូនដល់សហគមន៍មូលដ្ឋាន របស់គម្រោង **AFoCO** នឹងឆ្លុះបញ្ចាំងនូវការចូលរួមចំណែករបស់គម្រោងនៅក្នុងការចាប់ផ្តើម ដាំស្តារព្រៃឈើនៅក្នុងតំបន់គោលដៅរបស់គម្រោង។*"



*រូបភាព៖ លោកស្រី **លឹម សុភាព** ជាអនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃឈើដាំ និងព្រៃឯកជន និងជាមន្ត្រីគម្រោងចុះបញ្ជីចម្ការព្រៃឯកជននៅកម្ពុជា បានចុះចែកកូនឈើដល់សហគមន៍មូលដ្ឋាន នៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម។*

ប្រសិនបើអ្នកស្នើសុំ ឬម្ចាស់ចម្ការដើមឈើឯកជនបានគោរពតាមលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធទាំងការទទួលបានផ្លូវច្បាប់ និងលក្ខណៈវិនិច្ឆ័យវាយតម្លៃសម្រាប់ការដាំដើមឈើឯកជននោះ វិញ្ញាបនបត្រព្រៃឈើឯកជនត្រូវចេញឱ្យអ្នកស្នើសុំមិនលើសពីពីរខែបន្ទាប់ពីការដាក់ស្នើដំបូង។ ពាក្យសុំអាចត្រូវបានច្រានចោល ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកដាក់ពាក្យខកខានមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដែលទាក់ទងនឹងកម្មសិទ្ធិស្របច្បាប់ដល់ដី ហើយនឹងត្រូវតម្រូវឱ្យដាក់ស្នើពាក្យសុំឡើងវិញ។ ប្រសិនបើអ្នកស្នើសុំខ្វះឯកសារគាំទ្រដែលត្រូវការ ឬមិនអាចទទួលបានការផ្ទៀងផ្ទាត់វាលដែលពេញចិត្ត ឬអាចអនុលោមតាមលក្ខណៈវិនិច្ឆ័យវាយតម្លៃវាលសម្រាប់ចម្ការឯកជនរបស់ពួកគេនោះការចេញវិញ្ញាបនបត្រព្រៃឈើឯកជននឹងត្រូវផ្អាក។ គោលការណ៍ណែនាំក៏ចែងផងដែរថា ក្នុងការចុះបញ្ជីចម្ការព្រៃឈើឯកជន ម្ចាស់មិនតម្រូវឱ្យមានការអនុញ្ញាតក្នុងកម្មសិទ្ធរបស់ខ្លួន ដែលពាក់ព័ន្ធនឹងការប្រមូលផល ឬដឹកជញ្ជូនផលិតផលឈើដែលមានប្រភពចេញពីចម្ការឈើរបស់ពួកគេ លើកលែងតែផលិតផលដែលត្រូវបានគ្រោងនាំចេញ។




*រូបភាព៖ គោលការណ៍ណែនាំសម្រាប់ចុះបញ្ជី និងអភិវឌ្ឍន៍ព្រៃឯកជននៅកម្ពុជា (គ្របខាងមុខ និងខាងក្រោយ)*

## សារសំខាន់ និងការចូលរួមចំណែកនៅក្នុងការដាំស្តារព្រៃឈើ

ដើម្បីសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ រដ្ឋបាលព្រៃឈើបានព្យាយាមបង្កើនបរិមាណផលឈើដាំដែលអាចប្រមូលបានពី ២០០.០០០ម៣/ឆ្នាំ នៅឆ្នាំ២០១៩ ដល់ ៣០០.០០០ម៣/ឆ្នាំ នៅឆ្នាំ២០២៣។ លើសពីនេះទៀត រដ្ឋបាលព្រៃឈើ បាននឹងកំពុងអភិវឌ្ឍការងារដាំដុះព្រៃឈើឡើងវិញនៅលើផ្ទៃដីព្រៃរេចរឹល ដីនៅទំនេររបស់រដ្ឋ និងជំរុញឱ្យមានការចូលរួមដាំឈើនៅលើដីកម្មសិទ្ធិឯកជននូវប្រភេទឈើប្រណិត ឈើពាណិជ្ជកម្ម ដែលអាចធ្វើអាជីវកម្មក្នុងរយៈពេលវែង មធ្យម និងខ្លី សំដៅបង្កើតប្រភពផ្គត់ផ្គង់ផលឈើ និងឈើថាមពលចេញពីចម្ការឈើដាំ និងជួយបង្កើនកម្រិតជីវភាពរបស់ប្រជាជន ដើម្បីកាត់បន្ថយការពឹងផ្អែកអាស្រ័យផលឈើប្រភពចេញពីព្រៃធម្មជាតិ។

*លោកបណ្ឌិត **លី ម៉េងស៊ាង** បានបញ្ជាក់ថា៖ "រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន ដែលបានដាំដុះឈើ និងចុះបញ្ជីជាព្រៃឯកជន នឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចជា ការប្រឹក្សាលើបច្ចេកទេស និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការបញ្ចុះអត្រាអាករនាំចេញលើមុខទំនិញប្រភេទឈើដាំ និងវត្ថុធ្វើពីឈើដាំ ការអនុគ្រោះបន្ថយ ៥០% នៃកាតព្វកិច្ចអាករនាំចេញសរុប លើការនាំចេញមុខទំនិញប្រភេទឈើដាំ និងការដាក់អាករនាំចេញជាបន្ទុករដ្ឋ ចំពោះការនាំចេញមុខទំនិញគ្រឿងសង្ហារិម និងផលិតផលសម្រេចផ្សេងទៀតធ្វើពីឈើដាំក្នុងប្រទេស។"*



*រូបភាព៖ លោកបណ្ឌិត **លី ម៉េងស៊ាង** ចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពី "គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា" នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ដែលត្រូវបានរៀបចំតាម Zoom*

លោកស្រី **លឹម សុភាព៖** *"ការចុះបញ្ជីព្រៃឯកជន គឺជាការរួមចំណែកធានាដល់ការធ្វើពាណិជកម្មប្រភេទឈើនៅក្នុងឧបសម្ពន្ធសាយតេស ដោយបញ្ជាក់អំពីប្រភពច្បាស់លាស់ចេញពីចម្ការឈើដាំ។"*



*រូបភាព៖ លោកស្រី **លឹម សុភាព** បានចូលរួមចែក និងដាំឈើកូនឈើជាប្រព័ន្ធកសិ-រុក្ខកម្ម ជាមួយកសិករ នៅឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។*

*"រដ្ឋបាលព្រៃឈើបានរៀបចំនិតិវិធីក្នុងការចុះបញ្ជីព្រៃឯកជនដែលមានឯកសារពាក់ព័ន្ធ ដូចជាពាក្យស្នើសុំចុះបញ្ជីព្រៃឯកជន សៀវភៅបន្ទុក និងវិញ្ញាបនបត្រ ដែលអាចឆ្លើយតបទៅនឹងលក្ខខណ្ឌជាគោលការណ៍នៃអនុសញ្ញាសាយតេស ដែលបញ្ជាក់នូវប្រភពឈើស្របច្បាប់សម្រាប់ការធ្វើពាណិជ្ជកម្មផលិតផលឈើលើទីផ្សារអន្តរជាតិ។ ការចុះបញ្ជីចម្ការឈើដាំ ឬឈើដាំជាទម្រង់កសិ-រុក្ខកម្មនៅតាមផ្ទះប្រជាពលរដ្ឋ តាមទីជនបទក្នុងប្រទេសកម្ពុជា អាចជាការជំរុញលើកទឹកចិត្ត ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា ដែលរួមចំណែកនៅក្នុងការដាំស្តារឡើងវិញនូវប្រភេទឈើសំខាន់ៗ និងមានតម្លៃលើទីផ្សារ។"*



*រូបភាព៖ កញ្ញា **អ៊ួច ស៊ីនេត** អនុប្រធានការិយាល័យ នៃនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន និងជាមន្ត្រីគម្រោងចុះបញ្ជីចម្ការព្រៃឯកជននៅកម្ពុជា បានចុះប្រមូលទិន្នន័យឈើដាំ នៅខេត្តកំពង់ចាម*

## ចំណាប់អារម្មណ៍របស់សាធារណជន និងវិស័យឯកជន

ជាដំបូង មានការរំពឹងតិចតួចណាស់ ដែលថានឹងមានការស្នើសុំចុះបញ្ជីជាព្រៃឯកជនភ្លាមៗ បន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់នៅខែវិច្ឆិកា ឆ្នាំ២០២០ និងក្នុងអន្តរកាល ដែលគោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជានេះ កំពុងស្ថិតនៅក្នុងដំណាក់ការកែសម្រួល និងសុំគោលការណ៍ចុងក្រោយសម្រាប់ការបោះពុម្ពផ្សព្វផ្សាយ ព្រមទាំងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។ ប៉ុន្តែជាការគួរឱ្យចាប់អារម្មណ៍ គឺមានវិស័យឯកជនពិសេសក្រុមហ៊ុនចំនួន២ បានស្នើសុំចុះបញ្ជីចម្ការឈើដាំជាព្រៃឯកជន ដំបូងគេនៅកម្ពុជាដែលចំនួន៤ទីតាំងក្នុងរយៈពេលត្រឹម៦ខែ ក្នុងឆ្នាំ២០២១។ ទីតាំងទី១ ផ្ទៃដី ៨,៩២៣ហិកតា មានចំនួន១ទីតាំង (ដាំចន្ទន៍ក្រសា ក្រញូង បេង ធ្នង់) ស្ថិតនៅក្នុងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ និងទីតាំងចំនួន៣ ផ្សេងទៀត ដែលទីតាំងទី១ មានទំហំ២៨០ហិកតា (ដាំចន្ទន៍ក្រសា ក្រញូង និងក្រញូងហៃណាន់...) ស្ថិតក្នុងស្រុកស្រែអំបិល ខេត្តកោះកុង, ទីតាំងទី២មានទំហំ៣៣ហិកតា (ដាំចន្ទន៍ក្រសា ក្រញូង បេង) ស្ថិតក្នុងស្រុកទឹកឈូ ខេត្តកំពត និងទីតាំងទី៣មានទំហំ៣៧ហិកតា (ចន្ទក្រស្នា ក្រញូង បេង) ស្ថិតក្នុងស្រុកបន្ទាយមាស ខេត្តកំពត។

*កញ្ញា **អ៊ូច ស៊ីនេត**៖ "ផលជាវិជ្ជមាននេះ គឺជាភស្តុតាងដែលបង្ហាញថាវិស័យឯកជន បាននឹងកំពុងចាប់អារម្មណ៍យ៉ាងខ្លាំងអំពីការវិនិយោគលើចម្ការឈើដាំនៅកម្ពុជា ដែលដើរតួយ៉ាងចម្បង និងរួមចំណែកដ៏សំខាន់នៅក្នុងការអភិវឌ្ឍចម្ការឈើដាំ និងការស្តារព្រៃឈើនៅកម្ពុជា"*



*រូបភាព៖ កញ្ញា **អ៊ូច ស៊ីនេត** បានចូលរួមចែក និងដាំឈើកូនឈើជាប្រព័ន្ធកសិ-រុក្ខកម្ម ជាមួយកសិករ នៅឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។*

សម្រាប់ទិសដៅទៅអនាគត គម្រោងចុះបញ្ជីចម្ការព្រៃឯកជននៅកម្ពុជា មានផែនការសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន ដើម្បីបោះពុម្ព និងរៀបចំវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយសៀវភៅស្តីពីគោលការណ៍ណែនាំសម្រាប់ចុះបញ្ជី និងអភិវឌ្ឍន៍ព្រៃឯកជននៅកម្ពុជា ដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងវិស័យឯកជន ដើម្បីពង្រីកការចាប់អារម្មណ៍ និងជំរុញការចូលរួមពីសំណាក់វិស័យឯកជននៅក្នុងការវិនិយោគចម្ការឈើដាំ និងការចុះបញ្ជីព្រៃឯកជនឱ្យកាន់តែទូលំទូលាយ មានវិសាលភាពនៅទូទាំងកម្ពុជា។